**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំយន្តការគ្រប់គ្រង កម្រិតថ្នាក់ និងកំណត់ប្រាក់កម្រៃម៉ោងបង្រៀនសម្រាប់យោធាជន

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅ សម្រាប់កងយោធពលខេមរភូមិន្ទ

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួល រចនាសម្ព័ន្ធចាត់តាំង និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំយន្តការគ្រប់គ្រង កម្រិតថ្នាក់ និងកំណត់ប្រាក់កំរៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងដើម្បី ៖

- លើកកម្ពស់គុណភាពយោធាចារ្យ ក្នុងវិស័យការពារជាតិ
- ផ្តល់គុណភាពហ្វឹកហ្វឺនបណ្តុះបណ្តាលធនធានមនុស្សស្របតាមផែនការកែទម្រង់កងយោធពលខេមរភូមិន្ទ ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះយោធាចារ្យ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ និងគ្រូបង្រៀនសាស្ត្រាចារ្យ មន្ត្រីរាជការស៊ីវិល អ្នកច្បាប់ ឬអ្នកមានចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកទេសដែលបានអញ្ជើញមកឡើងថ្នាក់ឧទ្ទេសនាមបង្រៀនដល់សិក្ខាកាមគ្រប់វគ្គសិក្សានៅតាមសាកលវិទ្យាល័យ វិទ្យាស្ថាន សាលា និងមជ្ឈមណ្ឌលហ្វឹកហ្វឺនរបស់កងយោធពលខេមរភូមិន្ទ ។

## ជំពូកទី ២

## យន្តការគ្រប់គ្រង

**មាត្រា ៤.-**

យោធិនដែលបានទទួលស្គាល់ជាយោធាចារ្យ ត្រូវបានឆ្លងកាត់វគ្គបណ្តុះបណ្តាល ឬបំប៉នគរុកោសល្យយោធាចារ្យតាមមុខជំនាញ បច្ចេកទេសយោធា របស់កងយោធពលខេមរភូមិន្ទ ។

ការទទួលស្គាល់យោធាចារ្យគ្រប់កម្រិត សម្រេចដោយលិខិតបទដ្ឋានរបស់ក្រសួងការពារជាតិ ។

**មាត្រា ៥.-**

ការគ្រប់គ្រង វាយតម្លៃគុណភាពយោធាចារ្យ ត្រូវធ្វើឡើងដោយគណៈកម្មការ របស់ក្រសួងការពារជាតិ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

www.pheakdeylaw.com

**មាត្រា ៦.-**

ការតែងតាំង ផ្លាស់ប្តូរ តម្លើងឋានន្តរសក្តិ និងសរសើរជូនរង្វាន់យោធាចារ្យដែលបំពេញមុខងារនៅសាកលវិទ្យាល័យ វិទ្យាស្ថាន សាលា និងមជ្ឈមណ្ឌលហ្វឹកហ្វឺនមានដូចតទៅ ៖

- ត្រូវបំពេញភារកិច្ចរយៈពេល ៥ ឆ្នាំយ៉ាងតិចទើបអាចតែងតាំងផ្លាស់ប្តូរចេញពីក្របខ័ណ្ឌយោធាចារ្យបាន ។

- ការតម្លើងឋានន្តរសក្តិយោធាចារ្យត្រូវអនុវត្តតាមច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។

- ការសរសើរជូនរង្វាន់យោធាចារ្យត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ ។

## ជំពូកទី ៣

## កម្រិតថ្នាក់យោធាចារ្យ

**មាត្រា ៧.-**

ត្រូវបានរៀបចំកម្រិតថ្នាក់យោធាចារ្យដែលបំពេញមុខងារបង្រៀននៅក្នុងក្របខ័ណ្ឌសាកលវិទ្យាល័យ វិទ្យាស្ថាន សាលា និងមជ្ឈមណ្ឌលហ្វឹកហ្វឺន នៃកងយោធពលខេមរភូមិន្ទ មានដូចខាងក្រោម ៖

- កម្រិតបឋម
- កម្រិតមធ្យម
- កម្រិតឧត្តម

**មាត្រា ៨.-**

យោធាចារ្យតាមកម្រិតថ្នាក់នីមួយៗ ត្រូវបានកំណត់ដូចតទៅ ៖

- កម្រិតបឋម យោធាចារ្យដែលបំពេញមុខងារនៅក្នុងក្របខ័ណ្ឌសាលា មជ្ឈមណ្ឌលហ្វឹកហ្វឺន និងបណ្តុះបណ្តាលវិក្រឹតការនាយទាហានរង ពលទាហាន និងមុខជំនាញឯកទេសបឋម ។

- កម្រិតមធ្យម យោធាចារ្យដែលបំពេញមុខងារនៅក្នុងក្របខ័ណ្ឌវិទ្យាស្ថាន សាលា មជ្ឈមណ្ឌលហ្វឹកហ្វឺននិងបណ្តុះបណ្តាលនាយទាហានបឋម និងមុខជំនាញឯកទេសមធ្យម និងនាយមុខវិជ្ជាយោធាចារ្យកម្រិតបឋម ។

- កម្រិតឧត្តម យោធាចារ្យដែលបំពេញមុខងារនៅក្នុងក្របខ័ណ្ឌសាកលវិទ្យាល័យ វិទ្យាស្ថាន សាលាហ្វឹកហ្វឺន និងបណ្តុះបណ្តាលបរិញ្ញាបត្រ និងវគ្គវិក្រឹតការនាយទាហានជាន់ខ្ពស់ និងនាយមុខវិជ្ជាយោធាចារ្យកម្រិតមធ្យម ។

## ជំពូកទី ៤

## កំណត់ពេលម៉ោងបង្រៀន និងវិន័យ

**មាត្រា ៩.-**

ត្រូវបានកំណត់ពេលម៉ោងបង្រៀនជាកាតព្វកិច្ចយោធាចារ្យនៅក្នុងសាកលវិទ្យាល័យ វិទ្យាស្ថាន សាលា និងមជ្ឈមណ្ឌលហ្វឹកហ្វឺន នៃកងយោធពលខេមរភូមិន្ទ ដូចក្នុងតារាងខាងក្រោម ៖

www.pheakdeylaw.com

| ថ្នាក់សិក្សា | ចំនួនម៉ោងបង្រៀនផ្លូវការប្រចាំសប្តាហ៍ | ចំនួនម៉ោងណែនាំអនុវត្តរៀបចំការបង្រៀនកំណែប្រចាំសប្តាហ៍ |
|---|---|---|
| ★ -**<u>កម្រិតបឋម</u>** :<br>- ហ្វឹកហ្វឺនពលទាហាន<br>- បណ្តុះបណ្តាលនាយទាហានរង និងជំនាញឯកទេសបឋម | ១៨ ម៉ោង<br>១៦ ម៉ោង | ២០ ម៉ោង<br>១៨ ម៉ោង |
| ★ -**<u>កម្រិតមធ្យម</u>** :<br>- បណ្តុះបណ្តាលនាយទាហានថ្នាក់មូលដ្ឋាន និងជំនាញឯកទេសមធ្យម | ១៤ ម៉ោង | ១៨ ម៉ោង |
| ★ -**<u>កម្រិតឧត្តម</u>** :<br>- បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ និងវិក្រឹតការនាយទាហានជាន់ខ្ពស់ | ១២ ម៉ោង | ១៦ ម៉ោង |

**មាត្រា ១០.-**

ប្រាក់កំរៃម៉ោងបង្រៀនរបស់យោធាចារ្យ កងយោធពលខេមរភូមិន្ទ ក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌទៅតាមកម្រិតសញ្ញាបត្រ និងតាមក្របខ័ណ្ឌតួនាទីក្នុង១នាក់មិនឱ្យលើស៤៨ម៉ោងក្នុង១ខែ ត្រូវបានទទួលប្រាក់កំរៃម៉ោងបន្ថែមក្នុងមួយម៉ោងដូចមានក្នុងតារាង :

| កម្រិតសិក្សា / សញ្ញាបត្រ ឬឋានៈ | បណ្តុះបណ្តាល-បំប៉នកម្រិតបឋម | បណ្តុះបណ្តាល-បំប៉នកម្រិតមធ្យម | បណ្តុះបណ្តាល-បំប៉នកម្រិតឧត្តម |
|---|---|---|---|
| សាស្ត្រាចារ្យថ្នាក់បណ្ឌិត ឬថ្នាក់អគ្គនាយកឡើងទៅ | 0 | 0 | ១០.៤០០៛ |
| សាស្ត្រាចារ្យថ្នាក់អនុបណ្ឌិត ឬក្របខ័ណ្ឌ ឧ១.៤ ឬថ្នាក់នាយកដ្ឋាន | 0 | 0 | ៥.៣០០៛ |
| សាស្ត្រាចារ្យថ្នាក់ឧត្តម ឬក្របខ័ណ្ឌ ឧ១.១ ឧ១.៣ ឬថ្នាក់ប្រធានការិយាល័យ | ៥.២០០៛ | ៥.២០០៛ | ៧.៨០០៛ |
| សាស្ត្រាចារ្យថ្នាក់មធ្យម ឬក្របខ័ណ្ឌ ខ២ ខ១.៣ ឬថ្នាក់អនុប្រធានការិយាល័យចុះ | ២.៦០០៛ | ២.៦០០៛ | ២.៦០០៛ |

**មាត្រា ១១.-**

កំណត់ប្រាក់កំរៃចងក្រងឯកសារ និងបកប្រែភាសាបរទេសសម្រាប់បម្រើការហ្វឹកហ្វឺន រៀនសូត្រក្នុងមួយទំព័រឯកសារវាយកុំព្យូទ័រ ខ្នាតក្រដាស "A4" ត្រូវទទួលបានប្រាក់កំរៃដូចតទៅ :

- លើកិច្ចការស្រាវជ្រាវចងក្រង ចំនួន១០.០០០៛ ( ដប់ពាន់) រៀល ក្នុងមួយទំព័រ ។
- លើកិច្ចការបកប្រែឯកសារ ចំនួន៦.០០០៛ ( ប្រាំមួយពាន់) រៀល ក្នុងមួយទំព័រ ។

ដោយឡែកការសរសេរសលាកបត្រ ឬតែងការបង្រៀនមិនត្រូវបានគិតជាប្រាក់កំរៃឡើយ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

ការត្រួតពិនិត្យវាយតម្លៃគុណភាពយោធាចារ្យ ការតម្លើងកម្រិត ការបណ្តុះបណ្តាលបន្ថែម និងការងារស្រាវជ្រាវ ចងក្រង បកប្រែឯកសារសម្រាប់បម្រើការហ្វឹកហ្វឺនរៀនសូត្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ៨ ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com